CITY OF LONG BEACH PRESS RELEASE

សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី ១២ ខែមិថុនាឆ្នាំ ២០២០

ទំនាក់ទំនង៖ Jane Grobaty, Community Information Officer, Jane.Grobaty@longbeach.gov

សម្រាប់សេចក្តីប្រកាសជាបន្ទាន់

# មន្ទីរឧទ្យាននៃទីក្រុងឡុងប៊ិចផ្តល់ដល់កុមារនិងយុវជននូវកម្មវិធីសេវាកម្មអាហារនៅរដូវក្តៅរបស់ក្រសួងកសិកម្មនៃសហរដ្ឋអាមេរិក

ទីក្រុងឡុងប៊ិច,រដ្ឋកាលីហ្វ័រញ៉ា - ក្នុងរយៈពេល ៤១ ឆ្នាំជាប់ៗគ្នាមន្ទីរឧទ្យានកំសាន្តនិងសមុទ្រនៃទីក្រុងឡុងប៊ិច (PRM) នឹងផ្តល់ជូនកម្មវិធីសេវាកម្មស្បៀងអាហារនៅរដូវក្តៅ (Summer Food Service Program) របស់ក្រសួងកសិកម្មនៃសហរដ្ឋអាមេរិក (USDA) ដើម្បីផ្តល់អាហារបំប៉ននិងមានជីវជាតិដោយឥតគិតថ្លៃដល់កុមារនិងយុវវ័យនៅឡុងប៊ិចពេញមួយរដូវខែក្តៅ។

លោកអភិបាលក្រុង Robert Garcia បានមានប្រសាសន៍ថា "កម្មវិធីសេវាកម្មអាហារនៅរដូវក្តៅផ្តល់អាហារបំប៉នដល់កុមារក្នុងកំឡុងខែរដូវក្តៅនៅពេលសាលាមិនចូលរៀន។ ដោយសារតែបុគ្គលិកនៅមន្ទីរឧទ្យានកំសាន្តនិងសមុទ្រនៃទីក្រុងឡុងប៊ិចនិងដៃគូរបស់យើងនៅក្រសួងកសិកម្មនៃសហរដ្ឋអាមេរិកយុវជនរបស់យើងនឹងទទួលបានអាហារដោយឥតគិតថ្លៃចំនួនប្រាំថ្ងៃក្នុងមួយសប្តាហ៍នៅទីតាំងចំនួន ៣៣ កន្លែងនៅទូទាំឡុងប៊ិច។"

ចាប់ផ្តើមពីថ្ងៃទី ១៥ ខែមិថុនាដល់ថ្ងៃទី ២១ ខែសីហាឆ្នាំ ២០២០ មន្ទីរឧទ្យានកំសាន្តនិងសមុទ្រនៃទីក្រុងឡុងប៊ិចនឹងផ្តល់អាហារដោយឥតគិតថ្លៃដល់កុមារនិងយុវជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រវេលាម៉ោង ១១:៣០ ព្រឹកដល់ ១២:៣០ រសៀល (មិនរាប់បញ្ចូលថ្ងៃសុក្រទី ៣ ខែកក្កដាឆ្នាំ ២០២០ទេ)។ អាហារគឺ

មានសម្រាប់កុមារនិងយុវវ័យដែលមកចូលរួមទាំងអស់ដែលមានអាយុចាប់ពីមួយឆ្នាំទៅ ១៨ ឆ្នាំ។ អាហារសម្រាប់ទារកនឹងមិនផ្តល់ជូនទេ។

មន្ទីឧទ្យានកំសាន្តនិងសមុទ្រនៃទីក្រុងឡុងប៊ិចនឹងអនុវត្តសេវាកម្ម "Grab n Go" ដែលស្រដៀងនឹងអ្វីដែលផ្តល់ដោយ Long Beach Unified School District ក្នុងកំឡុងឆ្នាំសិក្សាគឺដែលអ្នកចូលរួមនឹងបានទទួលអាហារកកដែលអាចយកទៅកំដៅនៅផ្ទះបានតាមរយៈមីក្រូវ៉េវឬឡ (oven)។ អាហារក៏នឹងរួមបញ្ចូលនូវគ្រឿងត្រជាក់ដូចជាទឹកដោះគោទឹកផ្លែឈើនិងបន្លែ។

កម្មវិធីសេវាកម្មអាហារក្នុងរដូវក្តៅបានចាប់ផ្តើមនៅឡុងប៊ិចក្នុងឆ្នាំ ១៩៧៩ ហើយចាប់តាំងពីពេលនោះមកបានផ្តល់អាហារដល់យុវជនជាង ២ លាននាក់។

ដើម្បីចូលមើលបញ្ជីពេញលេញនៃទីតាំងដែលនឹងផ្តល់អាហារនិងសម្រាប់ព័ត៌មានបន្ថែមសូមចូលទៅកាន់គេហទំព័ររបស់ PRM ឬទូរស័ព្ទទៅការិយាល័យអាហារនៅរដូវក្តៅតាមលេខ 562.570.3226។

**អំពីទីក្រុងឡុងប៊ិច**

ជាទីលំនៅដ្ឋាននៃប្រជាជនប្រមាណ ៤៨០,០០០ នាក់ទីក្រុងឡុងប៊ិចបានទទួលពានរង្វាន់និងជាទីក្រុងច្នៃប្រឌិតដែលផ្តល់ជូននូវភាពសំបូរបែបនៃពិភពលោកខណៈពេលដែលរក្សាលក្ខណៈបុគ្គលនិងដែលបង្កើតឡើងពីសង្កាត់ផ្សេងៗពីគ្នាដែលបានផ្តុំនៅតាមបណ្តោយឆ្នេរសមុទ្រប៉ាស៊ីហ្វិក។ ក្នុងនាមជាទីក្រុងដែលមានសេវាកម្មពេញលេញទីក្រុងឡុងប៊ិចជាលំនៅដ្ឋានរបស់នាវា Queen Mary, អាងចិញ្ចឹមត្រីនៃមហាសមុទ្រប៉ាស៊ីហ្វិក (Aquarium of the Pacific), សារមន្ទីរនិងរោងកុនជាច្រើន, សាលារៀនដែលត្រូវបានវាយតម្លៃខ្ពស់, អាកាសយានដ្ឋានឡុងប៊ិច, កំពង់ផែឡុងប៊ិច ក៏ដូចជាមន្ទីរផ្សេងៗដែលបានទទួលពានរង្វាន់ជាច្រើនដូចជាមន្ទីរសុខាភិបាល មន្ទីរឧទ្យានការកំសាន្តនិងសមុទ្រ មន្ទីរសេវាកម្មអភិវឌ្ឍន៍ និងមន្ទីរផ្សេងៗទៀត។ ទីក្រុងនេះក៏មានសាកលវិទ្យាល័យនិងមហាវិទ្យាល័យដែលត្រូវបានការគោរពខ្ពស់ ក៏ដូចជាកន្លែងចិញ្ចឹមសត្វជាប្រវត្តិសាស្ត្រចំនួន២ មន្ទីរពេទ្យ៥ ទីតាំង៥សម្រាប់លេងហ្គោល សួន១៧០ ឆ្នេរសមុទ្រជាច្រើនម៉ាយល៍ម៉ា ផ្លូវសម្រាប់ជិះកង់ និងកម្មវិធីជិះកង់ដែលមានការចែករំលែក។

សម្រាប់ព័ត៌មានបន្ថែមអំពីទីក្រុងឡុងប៊ិចសូមចូលទៅកាន់គេហទំព័រ http://longbeach.gov/។ សូមតាមដានទីក្រុងឡុងប៊ិចនៅលើបណ្តាញសង្គមសម្រាប់ព័ត៌មានថ្មីៗនៅលើ ហ្វេសប៊ុក ធ្វីតធ័រ Instagram និង យូធ្យូប។

**អំពីមន្ទីឧទ្យានកំសាន្តនិងសមុទ្រនៃទីក្រុងឡុងប៊ិច**

មន្ទីឧទ្យានកំសាន្តនិងសមុទ្រនៃទីក្រុងឡុងប៊ិច (PRM) ត្រូវបានទទួលស្គាល់ចំពោះឧត្តមភាពក្នុងការអនុវត្តការគ្រប់គ្រងនិងកម្មវិធីដោយទទួលបានពានរង្វាន់មេដាយមាសឧទ្យាននិងសួនកំសាន្តជាតិបួនដង។ PRM ផ្តល់នូវកម្មវិធីនិងសេវាកម្មកម្សាន្តដល់ប្រជាជននិងភ្ញៀវទេសចរដែលធ្វើអោយគុណភាពជីវិតនៃការរស់នៅឡុងប៊ិចកាន់តែប្រសើរឡើង។ PRM ថែរក្សាឧទ្យានចំនួន 171 កន្លែងដែលមានមជ្ឈមណ្ឌលសហគមន៍ចំនួន 26 ទីធ្លាបើកចំហ 320 ហិចតានិងឆ្នេរ 6.1 ម៉ាយល៍ក៏ដូចជាអនុវត្តផែនការបើកលំហរបស់ទីក្រុងផ្តល់នូវឱកាសកំសាន្តដើម្បីបំពេញតំរូវការសហគមន៍ផ្សេងៗរក្សានូវសមុទ្រសាធារណៈនិងផ្តល់នូវសុវត្ថិភាពសាធារណៈនិងការព្យាបាលដោយមនុស្សធម៌ដល់សត្វ។

សម្រាប់ព័ត៌មានបន្ថែមអំពីមន្ទីឧទ្យានកំសាន្តនិងសមុទ្រនៃទីក្រុងឡុងប៊ិចសូមចូលទៅកាន់គេហទំព័រ http://www.longbeach.gov/park។ សូមតាមដានយើងខ្ញុំនៅលើបណ្តាញសង្គមដើម្បីទទួលបាននូវព័ត៌មានថ្មីៗតាមរយៈបណ្តាញសង្គមហ្វេសប៊ុក ធ្វីតធឺរ Instagram និងយូធ្យូប។

###